ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧៥
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩
សាលដីកា
លេខ: ១០៥ I
ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

# សាលដីកា
## គោរពនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន
២.ឯកឧត្តម [redacted] ចៅក្រម
៣.ឯកឧត្តម [redacted] ចៅក្រម
៤.ឯកឧត្តម [redacted] ចៅក្រម
៥.ឯកឧត្តម [redacted] ចៅក្រម
៦.ឯកឧត្តម [redacted] ចៅក្រម
៧.ឯកឧត្តម [redacted] ចៅក្រមរបាយការណ៍
៨.លោកជំទាវ [redacted] ចៅក្រម
៩.ឯកឧត្តម [redacted] ចៅក្រម

ក្រឡាបញ្ជីសវនាការ
លោក [redacted]

តំណាងមហាអយ្យការ
ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ

នៅលើបណ្ដឹងសាទុក្ខលេខ ២៧១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ត្រង់ចំណុចរួចផុតពីបទចោទប្រកាន់ ត្រង់ចំណុចទី២ នៃសេចក្ដីសម្រេចរបស់



Scanned with CamScanner

សាលាឧទ្ធរណ៍ និងចំណុចទី៣ ត្រង់បង្គាប់ឲ្យដោះលែងឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមកន់ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រII "ប" ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ ដែលមាន ៖

**ជនជាប់ចោទ៖**

១. ឈ្មោះ [redacted] ថន ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិរបុញ ឃុំត្រពាំងប្រសាទ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តព្រះវិហារ ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ទោសពីមុនគ្មាន ជាទីតិជន ។

- ឃុំខ្លួនតាមដីកាលេខ ២២៧២ ត.ព្រ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ។

២. ឈ្មោ [redacted] ស៊ិត ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិរបុញ ឃុំត្រពាំងប្រសាទ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឪពុកឈ្មោ [redacted]" ម្តាយឈ្មោ [redacted] "ស" នៅលីវ ទោសពីមុនគ្មាន ជាទីតិជន ។

- ឃុំខ្លួនតាមដីកាលេខ ២២៧១ ត.ព្រ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ។

៣. ឈ្មោះ [redacted] គុមគន់ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិឡាវ សញ្ជាតិឡាវ មានទីកន្លែងកំណើតស្រុកប៉ាគឹម នគរហ្លួង-វៀងចន្ទ ប្រទេសឡាវ មានទីលំនៅបច្ចុប្បន្ន [redacted] ប្រទេសឡាវ ប្រពន្ធឈ្មោះ [redacted] រ" មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

- ឃុំខ្លួនតាមដីកាលេខ ២២៧៣ ត.ព្រ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ។

- មានលោក [redacted] ម្ញូរ៉ា ជាមេធាវីការពារសិទ្ធិ។

៤. ឈ្មោ [redacted] ខាំបៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ សញ្ជាតិឡាវ មានទីកន្លែងកំណើតស្រុកប៉ាក់ថង ខេត្តចំប៉ាសាក់ ប្រទេសឡាវ មានទីលំនៅបច្ចុប្បន្ន [redacted] ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០៥នាក់ ឪពុកឈ្មោ [redacted] "រ" ម្តាយឈ្មោះ [redacted]" ទោសពីមុនគ្មាន ជាទីតិជន ។

- ឃុំខ្លួនតាមដីកាលេខ ២២៧០ ត.ព្រ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ។



Scanned with CamScanner

- មានលោក [redacted] ម៉ុរ៉ា ជាមេធាវីការពារសិទ្ធិ។

ត្រូវជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាផាលេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង ១៤ និង ១៥នាទី ដោយអនុវត្តវិធានញុះញង់ឲ្យលក់ខុសច្បាប់ នូវសារធាតុញៀន កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន និងមានការសម្របសម្រួលដោយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចុះប្រតិបត្តិការករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចសណ្ឋាគារបូលីណាផាលេស បន្ទប់លេខ៥០៣ ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ផង និងឈ្មោះ [redacted] ស៊ុត ពេលកំពុងធ្វើសកម្មភាពប្រព្រឹត្តបទល្មើសជាក់ស្តែង យកថ្នាំប្រភេទគ្រាប់ផ្កាឈូកសង្ស័យថា ជាគ្រឿងញៀន លាក់ទុកក្នុងកាបូប ទៅប្រគល់ឲ្យម៉ូយក្រោមការបញ្ជារពីឈ្មោះ ស្រស់ និងឈ្មោះ ផល្លី ព្រមទាំងដកហូតបានវត្ថុតាងប្រភេទថ្នាំគ្រាប់ពណ៌ផ្កាឈូកសង្ស័យថាគ្រឿងញៀនទម្ងន់ ១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) និងសម្ភារៈចាប់យករួមមានទូរស័ព្ទដៃម៉ាក S-WELCOM មួយគ្រឿង ។ លុះដល់វេលាម៉ោង ១៤ និង ២៥នាទី នាថ្ងៃខែឆ្នាំដដែល កម្លាំងចម្រុះបានបន្តធ្វើការឆែកឆេរបន្ទប់លេខ ១៣ ក្នុងផ្ទះសំណាក់ផ្កាមាស សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ ដែលជាអ្នកជួញដូរគ្រឿងញៀនជាមួយឈ្មោះ [redacted] ខាំ ជាជនជាតិភូមា និងឈ្មោះ ផល្លី ព្រមទាំងឈ្មោះ សម្រស់ តាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted]ង និងបានចាប់យកសម្ភារៈរួមមានរថយន្តមួយគ្រឿងម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, ទូរស័ព្ទដៃម៉ាក NOKIA ចំនួន មួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង, លិខិតឆ្លងដែនចំនួនពីរច្បាប់, កូនសៀវភៅចំនួនពីរក្បាល, ប័ណ្ណធនាគារចំនួនពីរច្បាប់ និងអត្តសញ្ញាណប័ណ្ណចំនួនមួយច្បាប់ ដើម្បីកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមច្បាប់ ។

-**បានឃើញ** សាលក្រមលេខ ០១ កប.១ “ឃ” ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម ៖



Scanned with CamScanner

ក. ឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិឡាវ

ខ. ឈ្មោះ[redacted] ខាំបៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន (២៣.១២.២០១២) និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន ៥០.០០០.០០០៛ (ហាសិបលាន) រៀល ដាក់ចូលថវិការដ្ឋ ។

ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារ ប៉ូលីណាផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ. ឈ្មោះ[redacted] ថង ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ

ឃ. ឈ្មោះ [redacted]ស៊ុត ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ២០ (ម្ភៃ) ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន (២៣.១២.១២) និង ពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន ៤០.០០០.០០០៛ (សែសិបលាន)រៀល ដាក់ចូលថវិការដ្ឋ ។

ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារ បូលីណាផាលេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.បណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទណ្ឌិតឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ អនុវត្តទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ចប់សព្វគ្រប់ជាស្ថាពរ តាមអំណាចសាលក្រមនេះរួចតាមមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ ។

៣. វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងពីចៅក្រមស៊ើបសួរលេខ ៧៧០វត ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ រួមមាន៖

ក. ប្រភេទថ្នាំគ្រាប់ពណ៌ផ្កាឈូកសង្ស័យថា គ្រឿងញៀនទម្ងន់ ១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) គប្បីសម្រេចរឹបអូសបំផ្លាញចោលតាមមាត្រា ៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. រថយន្តមួយគ្រឿងម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, រឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

គ. ទូរស័ព្ទដៃម៉ាក WELOM-S101 មួយគ្រឿង, ទូរស័ព្ទដៃម៉ាក NOKIA មួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង, លិខិតឆ្លងដែនចំនួនពីរក្បាល, កូនសៀវភៅចំនួនពីរក្បាល, កាតមានអក្សរឡាវមានលេខ៨៨៨៨៨៨៣០០០០២៥ ចំនួនមួយសន្លឹក, កាតមានអក្សរឡាវលេខA1-0040165 និង ស៊ីមកាតចំនួនប្រាំ ប្រគល់ឲ្យម្ចាស់ដើមនៃទ្រព្យវិញ តាមមាត្រា ៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទទាំងបួន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។ (ង.៨៧)

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ៨០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ឈ្មោ[redacted] ថង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ៨១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ឈ្មោះ[redacted]ស៊ុត ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ៨២ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ឈ្មោះ [redacted]ខាំបៃ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ៨៣ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ឈ្មោះ [redacted]គុមភន់ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** សាលដីកាលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨០,៨១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted]ថង, ឈ្មោះ[redacted] ស៊ុត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២. ទទួលបណ្តឹងលេខ ៨២,៨៣ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងរបស់ឈ្មោ[redacted] គុមភន់ ទុកជាត្រឹមត្រូវតាមច្បាប់ ។



Scanned with CamScanner

៣. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០១ កប១ "ឃ" ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] គុមភន់ ក្នុងចំណុចទី១ក ត្រូវកែប្រែពីទោសអនុវត្តពន្ធនាគារ ២៥ (ម្ភៃប្រាំឆ្នាំ) មកដាក់ពន្ធនាគារកំណត់ ២២ឆ្នាំ និងចំណុចទី១ខ ឈ្មោះ [redacted] ខាំបៃ ត្រូវកែប្រែលើទោសអនុវត្តក្នុងពន្ធនាគារ ២៥ ឆ្នាំ មកដាក់ពន្ធនាគារកំណត់២៤ ឆ្នាំ វិញ ។

ចំណុចផ្សេងពីនេះរក្សាទុកដដែល ។

៤. បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ចំពោះជនជាប់ចោទឈ្មោះ [redacted] ផង, ឈ្មោះ[redacted] ស៊ិត និងឈ្មោះ [redacted] ខាំបៃ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] គុមភន់ ប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥។

-បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។ (ឯ.១០០)

-**បានឃើញ** បណ្តឹងសាទុក្ខលេខ ២៧៣ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ របស់លោក[redacted] ទ្រី, និងឈ្មោះ [redacted] សុជាតិ ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោ[redacted]គុមភន់ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ឈ្មោ[redacted]ស៊ិត ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងសាទុក្ខលេខ ២៨៧ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ឈ្មោ[redacted] ខាំបៃ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងសាទុក្ខលេខ ២៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ឈ្មោះ[redacted]ង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** បណ្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រង់ចំណុចទី៣ នៃសេចក្តីសម្រេចទាំងមូល ។ (ឯ.១០៦)

-**បានឃើញ** សាលដីកាលេខ ៨៧ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់តុលាការកំពូលដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

Scanned with CamScanner

១.បដិសេធបណ្ដឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុត, បណ្ដឹងសាទុក្ខលេខ ២៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] ផង , និងបណ្ដឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាឧទ្ធរណ៍ ។

២.ទទួលបណ្ដឹងសាទុក្ខលេខ ២៨៧ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងបណ្ដឹងសាទុក្ខលេខ ២៧៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់លោក [redacted] ទ្រី និង លោក [redacted] សុជាតិ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] គុមភន់ ។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែសេចក្ដីសម្រេចត្រង់ចំណុចទី៣ នៃសាលដីកានេះ ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោ[redacted] ខាំបៃ ត្រូវបដិសេធចោល ។ (ឯ.១២៤)

-**បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រIIប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់តុលាការកំពូល ឲ្យជំនុំជំរះឡើងវិញ ក្រោយពីបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ២០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេច ដូចតទៅ ៖

១. ទទួលជំនុំជម្រះជាលើកទី២ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៣៧ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់តុលាការកំពូល។

២. ឱ្យឈ្មោះ [redacted] ខាំមៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ និងឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ ៣០ឆ្នាំ រួចផុតពីបទចោទប្រកាន់ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាផាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣. បង្គាប់ឱ្យដោះលែងជនត្រូវចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោ[redacted] គុមភន់ (មានសាវតារជាតិដូចខាងលើ) ពីពន្ធនាគារជាបន្ទាន់ បើអ្នកទាំងពីរនេះមិនត្រូវបានជាប់ឃុំពីបទល្មើសអ្វីផ្សេងទៀតទេ ។

៤. សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។ (ឯ.១៣៥)

Scanned with CamScanner

# នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៧ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់តុលាការកំពូល បានសម្រេចត្រង់ចំណុចទី៣ថា "តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV ប.ស ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែ សេចក្តីសម្រេចត្រង់ចំណុចទី៣ នៃសាលដីកា ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted]ខាំបៃ ត្រូវបដិសេធចោល ដោយលើកសំអាងហេតុ នៅត្រង់ចំណុចទី៤ នៃសាលដីកា និងសុំអោយសាលាឧទ្ធរណ៍ពិនិត្យពិចារណាចំណុចនេះឡើងវិញ។

-យល់ឃើញថា សាលដីការលើកទី២ លេខ ៦៥ ក្រII ប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ បានសម្រេចត្រង់ចំណុចទី២ ថា "ឲ្យឈ្មោះ [redacted] ខាំបៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ និងឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ រួចផុតពីបទចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាជាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនឹងផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយលើកសំអាងហេតុថា គ្មានពិរុទ្ធ លើជនជាប់ចោទឈ្មោះ [redacted]ខាំបៃ និងឈ្មោះ [redacted] គុមភន់ និងគោរពតាមការចង្អុលបង្ហាញរបស់តុលាការកំពូល។

-យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ រួចផុតពីបទចោទ ពុំត្រឹមត្រូវទេ ដោយហេតុថា:

១. សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ថន និងឈ្មោះ[redacted] ស៊ុត រួមទាំងគ្រឿងញៀន នៅសណ្ឋាគារបូលីណាជាឡេស នៅម៉ោង ១៤ និង១៥នាទី (ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២) ក្រោយពីសួរចម្លើយ [redacted] ថន សមត្ថិច្ចបានឈានទៅឃាត់ខ្លួន[redacted] គុមភន់ និងឈ្មោះ[redacted] ខាំបៃ នៅម៉ោង ១៤ និង១៥ នាទី (ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២) នៅផ្ទះសំណាក់ផ្កាមាស ។ ចំណុចនេះបង្ហាញថាមានតែក្រុមជនជាប់ចោទ ដែលដឹងពីកន្លែងដែលបក្សពួករបស់ខ្លួនស្នាក់នៅ។

Scanned with CamScanner

២.ជនជាប់ចោទបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាល ស្រាប់តែនៅពេលសវនាការបានឆ្លើយបដិសេធដោយលើកមូលហេតុដែលមិនគួរឱ្យជឿដូចជា ថា ខ្លួនភ័យពេកចេះតែឆ្លើយ ស្តាប់អ្នកបកប្រែមិនច្បាស់....។ល។ ការឆ្លើយបដិសេធនេះគ្មានភស្តុតាងស៊ីសង្វាក់ ពុំមានតម្លៃជាភស្តុតាងដែលគួរឱ្យជឿនោះឡើយ។

៣.តាមការបំភ្លឺរបស់លោកវរសេនីយ៍ឯក [redacted] ដារ៉ាត់ នាយផ្នែកនៃមន្ទីរប្រឆាំងគ្រឿងញៀន នៅមុខអង្គសវនាការសាលាដំបូងរាជធានីភ្នំពេញ ស្តីពីការប្រើវិធានការញុះញង់ ដោយបានការអនុញ្ញាតពីព្រះរាជអាជ្ញារង ឯកឧត្ត[redacted]ហួត បានបញ្ជាក់លំអិតពីសកម្មភាព របស់ជនជាប់ចោទនិងបក្សពួក និងបានចង្អុលច្បាស់ថាឈ្មោះ[redacted]ទាំបៃ និងឈ្មោះ[redacted] គុមរភន់ ជាមេខ្លោងនៃការជួញដូរនេះ។ ការឆ្លើយបំភ្លឺនេះមានភាពស៊ីសង្វាក់ និងមានតម្លៃគួរជឿបាន។

## <u>ហេតុដូច្នេះ</u>

## <u>តំណាងមហាអយ្យការប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច</u>

១. បដិសេធសាលដីកាលេខ ៦៥ ក្រII ប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ចោលជាអសាបង់។

២.សម្រេចតម្កល់សាលដីកាលេខ ១២២ “ក្រVបស” ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ទុកជាបានការ។

សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតាមច្បាប់។

+លោកមេធាវី [redacted] ឬរ៉ា ការពារជនជាប់ចោទឈ្មោ[redacted]ទាំបៃ និងឈ្មោះ[redacted]មរភន់ ធ្វើសេចក្តីសន្និដ្ឋានថា តាមអង្គហេតុ និងសំអាងហេតុទោះបីជាមានគ្រឿងញៀនច្រើនមែន ប៉ុន្តែមិនមានពាក់ព័ន្ធទាល់តែសោះចំពោះកូនក្តីខ្ញុំទាំងពីនាក់តាមមាត្រា ៤០ បទល្មើសគ្រឿងញៀន មិនបានកើតឡើងទេ ។

ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារអ្នកទាំង២នាក់នេះសុំបដិសេធបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសុំតម្កល់សាលដីកាលេខ ៦៥ ក្រII ប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

ហើយខ្ញុំបាទបានដាក់សេចក្តីសន្និដ្ឋានចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ក្នុងសំណុំរឿងរួចហើយ សុំក្រុមប្រឹក្សាពិនិត្យ និងសម្រេច ។



Scanned with CamScanner

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៧១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និង ជនជាប់ចោទឈ្មោះ [redacted] គុមភន់ រួចផុតពីបទចោទប្រកាន់ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារ បូលីណាផាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបង្គាប់ឱ្យដោះលែងជនត្រូវចោទទាំងពីរនាក់នេះ ពីពន្ធនាគារជាបន្ទាន់ បើអ្នកទាំងពីរនេះ មិនត្រូវបានជាប់ឃុំពីបទល្មើសអ្វីផ្សេងទៀតទេ ដោយសំអាងដូចមានក្នុងសំអាងហេតុត្រង់ចំណុចទី៣, ទី៤, ទី៥, ទី៦ និងទី៧ នៃសាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រIIប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់ខ្លួននោះ ជាការភ័ន្តច្រឡំ ពីព្រោះថាបណ្តឹងសាទុក្ខលើកទី១ គឺមានជនជាប់ចោទ ៤នាក់ ជាអ្នកប្តឹងសាទុក្ខ គឺ ១-ជនជាប់ចោទឈ្មោះ [redacted] ផង ២-ជនជាប់ចោទឈ្មោះ [redacted] ស៊ុត ៣-ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និង ៤-ជនជាប់ចោទឈ្មោះ [redacted] គុមភន់ ហើយជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងជនជាប់ចោទឈ្មោះ [redacted] គុមភន់ ត្រូវបានតុលាការអង្គសេចក្តីសម្រេច ប្រកាសទណ្ឌកម្មខ្ពស់ជាងជនជាប់ចោទពីរនាក់ទៀត គឺជនជាប់ចោទឈ្មោះ [redacted] ផង និងជនជាប់ចោទឈ្មោះ [redacted] ស៊ុត ដោយសំអាងថា ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងជនជាប់ចោទឈ្មោះ [redacted] គុមភន់ ***គឺជាមេផ្តើមគំនិត និងជាម្ចាស់គ្រឿងញៀន*** ប៉ុន្តែតុលាការកំពូលពិនិត្យមើលឃើញខ្លឹមសារនៃលិខិត ៤៨៩ របគ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ របស់មន្ទីរប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា ឈ្មោះ ផល្លី, សម្រស់ និងឈ្មោះ [redacted] ខាំ គឺ ជាមេក្លោងរកស៊ីជួញដូរគ្រឿងញៀនឆ្លងដែនខុសច្បាប់ទៅវិញ។ រីឯឈ្មោះ [redacted] ខាំបៃ និងជនជាប់ចោទឈ្មោះ [redacted] គុមភន់ គឺជាតួកូន ជាមួយ។ ក្នុងន័យនេះហើយ បានជាតុលាការកំពូល សម្រេចបង្វិលចំណុចនេះឱ្យសាលាឧទ្ធរណ៍ ធ្វើការពិចារណាឡើង

វិញ។ រីឯការប្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោ[redacted] ផង និងជនជាប់ចោទឈ្មោះ[redacted] ស៊ុត ត្រូវបានតុលាការកំពូលបដិសេធចោល ហើយសម្រេចតម្កល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍លើកទី I។

៣-យល់ឃើញថា តាមកំណត់ហេតុស្តាប់ចម្លើយលេខ ០៧១ និងលេខ ០៧២ កណប ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ របស់មន្ត្រីនគរបាលយុត្តិធម៌ ឈ្មោះ[redacted] គុមភន់ និងឈ្មោះ[redacted] ខាំបៃ បានឆ្លើយថា បានជាសមត្ថកិច្ចឃាត់ខ្លួន មកពីពួកខ្លួនបានរកស៊ីជួញដូរគ្រឿងញៀនខុសច្បាប់ ហើយបក្សពួករកស៊ីគ្រឿងញៀនខុសច្បាប់នោះ រួមមាន [redacted] ខាំ, សម្រស់, ផល្លី និងឈ្មោះ [redacted] ផង។ ដូច្នេះ ចម្លើយរបស់ឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ ស្របគ្នាទៅនឹងលិខិតលេខ ៤៨៩ រ.ប.ក ចុះថ្ងៃទី២៦ខែធ្នូ ឆ្នាំ២០១២ របស់មន្ទីរប្រឆាំងគ្រឿងញៀន និងលិខិតលេខ ១០០១ អ.ត ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ របស់មន្ទីរប្រឆាំងគ្រឿងញៀន ដែលថា មេក្លោងជួញដូរគ្រឿងញៀនថា ឈ្មោះ[redacted] ផង ឈ្មោះ [redacted] ស៊ុត ឈ្មោះ [redacted] គុមភន់ និងឈ្មោះ[redacted] ខាំបៃ ជាបក្សពួកក្រុមតែមួយ ពិតជាបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមែន ចំណែកឯឈ្មោះ[redacted] ខាំ ជាមេក្លោងជួញដូរគ្រឿងញៀន ។

៤-យល់ឃើញថា ផ្អែកតាមអង្គហេតុ និងភស្តុតាងខាងលើ គឺបានបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោ[redacted] ខាំបៃ ដែលបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ។ ដោយជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ ជាបក្សពួកក្នុងក្រុមតែមួយជាមួយឈ្មោះ[redacted] ផង និងឈ្មោ[redacted] ស៊ុត មិនមែនជាអ្នកផ្តើមគំនិត និងជាម្ចាស់គ្រឿងញៀនទេ ដូច្នេះ គប្បីតុលាការកំពូលពិចារណា និងសម្រេចផ្តន្ទាទោសឲ្យមានលក្ខណៈសមស្របដូចការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ផង និងជនជាប់ចោទឈ្មោ[redacted] ស៊ុត ផងដែរ ។

៥-យល់ឃើញថា បណ្តឹងសាទុក្ខរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មានមូលហេតុស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រII ប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ខុសនឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ២៧៦ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

Scanned with CamScanner

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៦៥ក្រII ប ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

៣-ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក/ឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ

ខ/ឈ្មោ[redacted] មាំបៃ ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិឡាវ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ ចំនួន ២០ (ម្ភៃ) ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន (២៣-១២-២០១២) និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដាក់ចូលថវិការដ្ឋ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារប្លូលីណាផាឡេស ផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-បង្គាប់ឲ្យអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួន ជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted]មាំបៃ។

៥-បណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទណ្ឌិតឈ្មោ[redacted] គុមភន់ និងឈ្មោះ វង្ស [redacted] មាំថៃ អនុវត្តទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ចប់សព្វគ្រប់ជាស្ថាពររួច តាមអំណាចសាលដីកានេះ តាមមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ។

សាលដីកានេះ ជំនុំជំរះសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |

.............................................................................................................

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

រាជធានីភ្នំពេញ, ថ្ងៃទី ...... ខែ ...... ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី ...... ខែ ...... ឆ្នាំ២០២១

ប្រធានអង្គជំនុំជម្រះ

[redacted]



Scanned with CamScanner